**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ ២៧១ ........ បទ ........................

# សេចក្តីបំភ្លឺ
## ទាក់ទងនឹងករណីបទល្មើសតាមប្រព័ន្ធទូរគមនាគមន៍ ប្រព្រឹត្តដោយជនជាតិ កូរ៉េ ១០ នាក់

ថ្មីៗនេះ មានសារព័ត៌មានមួយចំនួន បានចុះផ្សាយព័ត៌មានជុំវិញករណីជនជាតិកូរ៉េចំនួន ១០ នាក់ ដែលត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាត់ទោសឲ្យជាប់ពន្ធនាគារម្នាក់មួយឆ្នាំ ពីបទ "ចូលរួមនៅក្នុងក្រុម ឬឃុបឃិតក្នុងការប្រព្រឹត្តបទល្មើស" កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥។

ពាក់ព័ន្ធនឹងករណីនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សូមធ្វើការបំភ្លឺជូនសាធារណជនបានជ្រាបដូចតទៅ ៖

**១-ដំណើរដើមទងនៃសំណុំរឿងជនជាតិកូរ៉េទាំង ១០ នាក់**

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និងស៊ើបអង្កេតយ៉ាងហ្មត់ចត់រួចមក អគ្គាធិការដ្ឋាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សហការជាមួយអង្គភាពនគរបាលប្រឆាំងភេរវកម្មនៃក្រសួងមហាផ្ទៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងអាជ្ញាធរមូលដ្ឋាន បានចុះឆែកឆេរផ្ទះលេខ ១៩ ផ្លូវលេខ៥៥២ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងឃាត់ខ្លួនជនជាតិកូរ៉េ ១០ នាក់ ដោយសង្ស័យពីបទប្រមូលផ្តុំគ្នាប្រព្រឹត្តបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងរឹបអូសបាននូវវត្ថុតាងបំរើឲ្យការប្រព្រឹត្តបទល្មើសមួយចំនួនធំ ក្នុងនោះមាន៖ កុំព្យូទ័រយួរដៃ, ទូរស័ព្ទដៃ, ទូរស័ព្ទអចល័ត, ឧបករណ៍ WiFi, ឧបករណ៍ Switch ប្រភេទតូច និងធំ ។ល។ ក្រោយប្រតិបត្តិការខាងលើ ទាំងជនសង្ស័យជាជនជាតិកូរ៉េ ១០ នាក់ (ស្រី ៥ នាក់) និងវត្ថុតាងត្រូវបានអង្គភាពនគរបាលប្រឆាំងភេរវកម្មនៃក្រសួងមហាផ្ទៃ យកទៅដំណើរការតាមនីតិវិធីបន្ត រហូតដល់មានការកាត់ទោសដោយសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦ ខែសីហាកន្លងទៅនេះ។

**២-អំពីការលើកឡើងថា ជនជាតិកូរ៉េទាំង ១០ នាក់ បានជ្រៀតចូលក្នុងគេហទំព័រ និងប្រព័ន្ធទិន្នន័យរបស់ក្រសួង ដើម្បីលួចស្តាប់ការសន្ទនាគ្នាតាមទូរស័ព្ទរបស់សាធារណជន**

ចំពោះចំណុចនេះ ក្រសួងសូមអះអាងថា គឺជាការលើកឡើងដែលគ្មានការពិតទាល់តែសោះ ពីព្រោះ ៖

- ក្នុងរយៈពេលកន្លងទៅ គេហទំព័រផ្លូវការរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនគមន៍ ពុំធ្លាប់ត្រូវបានជ្រៀតចូល ឬវាយប្រហារពីមជ្ឈដ្ឋានណាមួយឡើយ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គ្មានទេនូវរបស់ដែលហៅថា "ប្រព័ន្ធទិន្នន័យ ឬប្រព័ន្ធឌីជីថលសម្រាប់ថតសម្លេង និងតាមដានស្តាប់ការសន្ទនាគ្នាតាមទូរស័ព្ទរបស់សាធារណជន" ហើយសកម្មភាពដូចបានលើកឡើងខាងលើនេះ មិនមែនជាអាណត្តិរបស់ក្រសួងឡើយ។

**រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥**